ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមហាផ្ទៃ
សាលាខេត្តព្រៃវែង
លេខ ០២៥ សខព /១១

# សេចក្តីជូនដំណឹង
## ស្តីពី
## ការប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់

## អភិបាលនៃគណៈអភិបាលខេត្តព្រៃវែង
## ជំរាបមក

ឯកឧត្តម លោកឧកញ៉ា លោកជំទាវ លោក លោកស្រី ជាម្ចាស់កម្មសិទ្ធិ មានដីធ្លីមិនបានប្រើប្រាស់ ស្ថិតនៅក្នុងខេត្តព្រៃវែង ជ្រាបថា៖

ដោយអនុលោមតាមអនុក្រឹត្យលេខ ៥៨ អនក្រ ចុះថ្ងៃទី ២៥ ខែកក្កដា ឆ្នាំ១៩៩៥ ស្តីពីការប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់ ប្រកាសលេខ ២២៤ ប្រក.សហវ.ពដ ចុះថ្ងៃទី ០៥ ខែកក្កដា ឆ្នាំ១៩៩៦ ស្តីពីការប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់ និង ប្រកាសលេខ ៤៥២ សហវ.ប្រក.ពដ ចុះថ្ងៃទី ០៦ ខែមិថុនា ឆ្នាំ២០០៧ ស្តីពីការកែប្រែប្រកាសស្តីពីការប្រមូលពន្ធលើដីធ្លី មិនបានប្រើប្រាស់។

សាលាខេត្តព្រៃវែង សូមគោរពអញ្ជើញ ឯកឧត្តម លោកឧកញ៉ា លោកជំទាវ លោក លោកស្រី ដែលជាម្ចាស់កម្មសិទ្ធិដីធ្លីមិនបានប្រើប្រាស់ មកកាន់សាខាពន្ធដារខេត្តព្រៃវែង ដើម្បី ដាក់លិខិតប្រកាសបង់ពន្ធលើដីធ្លីមិនបានប្រើប្រាស់ សម្រាប់ឆ្នាំ ២០១១ ឲ្យបានមុនថ្ងៃទី ៣០ ខែកញ្ញា ឆ្នាំ ២០១១។

ការបង់ពន្ធយឺត ឬមិនបានដាក់លិខិតប្រកាសពន្ធ ត្រូវរងទោសទណ្ឌតាមបទប្បញ្ញត្តិស្តីពីសារពើពន្ធ។

សាលាខេត្តព្រៃវែងសូមបញ្ជាក់ថា ចំណូលពន្ធលើដីធ្លីមិនបានប្រើប្រាស់ ជាគុណប្រយោជន៍ដល់ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ (រាជធានី-ខេត្ត-ក្រុង-ស្រុក-ខ័ណ្ឌ-ឃុំ-សង្កាត់) សម្រាប់អភិវឌ្ឍមូលដ្ឋាន។

សាលាខេត្តព្រៃវែង សង្ឃឹមនិងជឿជាក់ថា ឯកឧត្តម លោកឧកញ៉ា លោកជំទាវ លោក លោកស្រី ដែលជាកម្មសិទ្ធិករ ពិតជាយកចិត្តទុកដាក់បំពេញកាតព្វកិច្ចបង់ពន្ធជូនរដ្ឋជាពុំខានឡើយ។

ព្រៃវែង,ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១១

**អភិបាលនៃគណៈអភិបាលខេត្ត**

**អ៊ុំ សាមី**

**កន្លែងទទួល៖**
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងរៀបចំដែនដីនគរូបនីយកម្ម សំណង់និងសុរិយោដី
- គណៈកម្មការវាយតម្លៃដីធ្លីមិនបានប្រើប្រាស់
- ក្រុមប្រឹក្សាខេត្តព្រៃវែង
  (គោរពជូនជ្រាប)
- អនុគណៈកម្មការវាយតម្លៃដីធ្លីមិនបានប្រើប្រាស់
- អភិបាលនៃគណៈអភិបាលស្រុក-ក្រុង
  (ដើម្បីមុខការ)
- ឯកសារ-កាលប្បវត្តិ